# ការគាំទ្រគម្រោង សន្តិសុខស្បៀងនៅខេត្តមណ្ឌលគិរី

June 02-25, 2010
By Yim Sok Sophors

ចាប់ពីថ្ងៃទី ២២ ដល់ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១០ លោកបណ្ឌិត យ៉ង សាំងកុមារ ប្រធានអង្គការ សេដាក រួមជាមួយលោក យី គីមថាន នាយកកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាននៃអង្គការ សេដាក និងលោក យឹម សុខសុភាស់ អ្នកសម្របសម្រួលគម្រោងសន្តិសុខស្បៀងនៅខេត្តមណ្ឌលគិរីបានចុះគាំទ្រដល់គម្រោងសន្តិសុខស្បៀងនៅខេត្តមណ្ឌលគិរី។
នៅក្នុងពេលចុះគាំទ្រនោះ លោកបណ្ឌិត យ៉ង សាំងកុមារ បានធ្វើការបណ្តុះបណ្តាលដល់បុគ្គលិកគម្រោង រួមទាំងមានការ ចូលរួមពីបុគ្គលិកមន្ទីរកសិកម្មខេត្តមណ្ឌលគិរី និងជំនួយការនៅតាមមូលដ្ឋានដែលបានជ្រើសរើសដោយអង្គការ សេដាក។



សិក្ខាកាមបានរៀនសូត្របានច្រើនពីទ្រឹស្តីនិងការអនុវត្តន៍សម្រាប់ការអភិវឌ្ឍន៍ខ្លួនឯង ដូចជាទ្រឹស្តី ស ម ច ល (សុខភាព មិត្តភាព ចំណេះដឹង លុយ) ក៏ដូចជាបានរៀនសូត្រពីការពង្រីករង្វង់ឥទ្ធិពល ជំនាញសម្របសម្រួល របៀបនៃការប្រើប្រាស់សំណួរ ការវិភាគពីចំណុចខ្លាំង ចំណុចខ្សោយ ចំណុចដែលត្រូវបញ្ឈប់ ចំណុចដែលត្រូវធ្វើបន្ថែម ចំណុចកែលម្អជាដើម។ការបណ្តុះបណ្តាលនេះវាបានជួយអោយបុគ្គលិកបង្កើនស្មារតីយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍន៍ខ្លួនឯង បានបង្កើននូវជំនាញនិងរបៀបធ្វើការជាមួយកសិករ ជាពិសេសជនជាតិដើមភាគតិច(ភ្នង)នៅក្នុងតំបន់គោលដៅរបស់គម្រោង។
បុគ្គលិកទាំងនោះសន្យានឹងយកអ្វីដែលបានរៀនសូត្រទៅសាកល្បង និងអនុវត្តនៅតាមសហាគមន៍របស់ខ្លួន។